ក

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៥-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០៨ ស្តីពីការតែងតាំងជាទីប្រឹក្សានិងជំនួយការ សម្តេច អគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ ចំនួន ២៧ រូប ៨២

០៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០៩ ស្តីពីការតែងតាំងឯកឧត្តម **សាយ បូរិន** និង ឯកឧត្តម **អ៊ុំ វណ្ណា** ជា ឧកញ៉ា ៨៤

០៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១០ ស្តីពីការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៤ រូប ៨៥

០៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១១ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០២ រូប នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ៨៦

០៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១២ ស្តីពីការតែងតាំងឯកឧត្តម **ឃី តាំងលីម** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ ៨៧

០៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១៥ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូន នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៧ រូប ៨៨


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


០៥-០១-២០០៩ -អនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពីការបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ ៩០

០៨-០១-២០០៩ -អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពីការដំឡើងការិយាល័យអាជីវកម្មរ៉ែ និងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែ ទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ៩៥

០៥-០១-២០០៩ -អនុក្រឹត្យលេខ ០១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩៧

០៥-០១-២០០៩ -អនុក្រឹត្យលេខ ០២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៨

០៥-០១-២០០៩ -អនុក្រឹត្យលេខ ០៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៩

០៥-០១-២០០៩ -អនុក្រឹត្យលេខ ០៤ អនក្រ.តត ស្តីពីការបញ្ចប់តំណែងមន្ត្រីរាជការ ១០៤

០៥-០១-២០០៩ -អនុក្រឹត្យលេខ ០៥ អនក្រ.តត ស្តីពីការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ១០៥
០៦-០១-២០០៩ -អនុក្រឹត្យលេខ ០៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០៦
០៦-០១-២០០៩ -អនុក្រឹត្យលេខ ០៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១០៩
០៦-០១-២០០៩ -អនុក្រឹត្យលេខ ០៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១១១
០៦-០១-២០០៩ -អនុក្រឹត្យលេខ ០៩ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ១១២
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ១១៣
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១១៤
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១១៧
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ ១២០
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២១
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១៥ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១២៤
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១២៥
០៦-០១-២០០៩ -អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៨
០៨-០១-២០០៩ -អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយស ១៣៩
០៨-០១-២០០៩ -អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយស ១៥៧
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៥៩
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦០
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦១
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦២
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦៣
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៥
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៦
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៧
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ១៦៨
០៨-០១-២០០៩ -អនុក្រឹត្យលេខ ២៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៩

## ២-សេចក្តីសំរេច

០៨-០១-២០០៩ -សេចក្តីសំរេចលេខ ០១ សសរ ស្តីពីការបង្កើតគណៈករណីស្រាវជ្រាវស៊ើបអង្កេត ការកសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ ១៧០

## III-ការខារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៨-០១-២០០៩ -ប្រកាសលេខ ០៦៨ សហវ.ប្រក ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា ១៧២

០៥-០១-២០០៩ -សារាចរណែនាំលេខ ០០១ សហវ ស្តីពីការអនុវត្តថវិកាខេត្ត ក្រុង ឆ្នាំ ២០០៩ ១៧៥

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤ ។

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំង ជាទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ :

**ក-ទីប្រឹក្សា :**

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **នុត សារាន** | មានឋានៈស្មើ | **រដ្ឋមន្ត្រី** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២- ឯកឧត្តម | **ឡេង ប៉េងឡុង** | មានឋានៈស្មើ | **រដ្ឋមន្ត្រី** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣-ឯកឧត្តម | **ជា សុខុម** | មានឋានៈស្មើ | **រដ្ឋមន្ត្រី** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤-ឯកឧត្តម | **សោម ចាន់ជារ៉ុង** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥-ឯកឧត្តម | **ម៉ោក សុផារិន** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៦-ឯកឧត្តម | **ម៉ុក ចំណាន** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៧-ឯកឧត្តម | **អោម ចន** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៨-ឯកឧត្តម | **ប៊ុត គឹមស៊ាន** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៩-ឯកឧត្តម | **សំ ប៊ុណ្ណារិន** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |

១០-ឯកឧត្តម ម៉ៅ ទុន្សី មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១១-ឯកឧត្តម សោម សារី មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១២-ឯកឧត្តម ឡុង ណារិទ្ធ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៣-ឯកឧត្តម គីម ខួន មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៤-ឯកឧត្តម ស៖ សម្បត្តិ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៥-ឯកឧត្តម ស៊ៀង ពិសិដ្ឋ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៦-ឯកឧត្តម ទាំ សុធា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៧-ឯកឧត្តម ពេជ្រ កៅ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៨-ឯកឧត្តម ឆៀម លីមអៀង មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៩-ឯកឧត្តម ជាំ ពិសិដ្ឋ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២០-ឯកឧត្តម កុយ ទិសាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២១-ឯកឧត្តម នាង ផាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២២-ឯកឧត្តម ឡោ សុជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៣-ឯកឧត្តម អ៊ុច សំអុល មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៤-ឯកឧត្តម ឆាឌីល ខាន់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៥-ឯកឧត្តម សំ សារ៉ែន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

ខ-ជំនួយការៈ

១-ឯកឧត្តម តុប សារឿន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម ឈុប ផាន់ណារ៉ា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា២** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

*៣រ៧.០៩០១.០០៩*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩*

លេខ : ១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

១- ឯកឧត្តម សាយ បូរិន

២- ឯកឧត្តម អ៊ុំ ចណ្ណា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧.០៩០១.០០៩ នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៩*

លេខ: ១៥ .ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ជិនកេន

នស/រកត/០១០៩/០១០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទៈ

**ក_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក**

១-ឧត្តមសេនីយ៍ទោ ឈុន សារឿន អត្តលេខ ០០០៥៣៤

២-ឧត្តមសេនីយ៍ទោ អន នាត អត្តលេខ ០០០២១០

**ខ_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី កង ឈុន អត្តលេខ ០០៤២៥៨

២-ឧត្តមសេនីយ៍ត្រី ឡុង វិចិត្រ អត្តលេខ ០០០៤៥៨

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល.០៩០១.០១០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩*

លេខ : ១៧ . ច.ល

**ចំលងចេញពីច្បាប់ដើម**

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ស៊ុន ចាន់ថុល

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីស្តង់ដារកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្តម **មុំ សឺន** ឱ្យបំពេញមុខងារជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន

២. ឯកឧត្តម **ពិន ស៊ីទឡាយ** ឱ្យបំពេញមុខងារជាប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា មានឋានៈស្មើ **អគ្គនាយក**។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រ/ក.០៩០១.០១១

លេខ : ១ ៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩

នស/រកត/០១០៩/០១២

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម ឃី ផាន់រ៉ា ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.០៩០១.០១២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩*

លេខ : ១៧. ច.ល

បានឃើញ សម្រាប់ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០១៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

១- លោកវរសេនីយ៍ឯក **ចាន់ ឆាយ** អត្តលេខ ០១៤៣
២- លោកវរសេនីយ៍ឯក **យាង ឯក** អត្តលេខ ០៥៩០
៣- លោកវរសេនីយ៍ឯក **ឯក សោម** អត្តលេខ ០៦៨១
៤- លោកវរសេនីយ៍ឯក **ហេង សៀម** អត្តលេខ ០៧១៤
៥- លោកវរសេនីយ៍ឯក **ឆាយ សាម៉េត** អត្តលេខ ០៧៩៣
៦- លោកវរសេនីយ៍ឯក **ប៉ែន ចាន់ថុល** អត្តលេខ ០៨១៨

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧- លោកវរសេនីយ៍ឯក **ជី ឡុង** អត្តលេខ ០៦៥៨៤ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣៩ល.០៩០១.០១៥*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩*

លេខ : ១៦. ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០១ . អនក្រ . បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ-រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីសន្តិសុខនាវា និងសន្តិសុខបរិវេណ-កណ្តាលផែ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ត្រូវបានបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ ដើម្បីធានាការងារអាជីវកម្ម ការថែរក្សាសន្តិសុខនាវាចរ សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថានល្អនៅក្នុងមណ្ឌលនេះ ។

# ជំពូកទី ២

## ការកំណត់ព្រំប្រទល់មណ្ឌលអាជីវកម្មផែភ្នំពេញ

**មាត្រា ២:_**

ព្រំប្រទល់មណ្ឌលអាជីវកម្មផែភ្នំពេញរួមមាន បីតំបន់ដូចខាងក្រោម ÷

**តំបន់ទី១ : ភ្នំពេញ ចតុមុខ ( ទន្លេសាប-មេគង្គ )**

១-ព្រំប្រទល់ផ្ទៃទឹក

ក- ខាងជើង

-ផ្នែកទន្លេសាប : ត្រើយខាងលិច ត្រឹមខ្សែស្របរយៈទទឹងខាងជើង ១២៨៣០០០ ជាប់ព្រំប្រទល់ខាងជើងរបស់ស្ថានីយស្តុកប្រេងឥន្ធនៈសូតិម៉ិច ។ ត្រើយខាងកើត ចំភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

-ផ្នែកទន្លេមេគង្គ : ត្រើយខាងលិច ត្រឹមខ្សែស្របរយៈទទឹងខាងជើង ១២៨៤០០០ ចំភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ត្រើយខាងកើតចំភូមិព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្ត-កណ្តាល។

ខ- ខាងត្បូង

-ផ្នែកទន្លេបាសាក់ : ត្រឹមមាត់ទន្លេបាសាក់ ដែលបែកចេញពីចតុមុខ។

-ផ្នែកទន្លេមេគង្គ : ត្រឹមខ្សែរយៈបណ្តោយខាងកើត ៤៩៧០០០ ត្រង់ឃុំអរិយក្សត្រ និងឃុំវាលស្បូវ ។

២-ព្រំប្រទល់ផ្ទៃដីមាត់ទន្លេ

ក-ផ្នែកភ្នំពេញ : ត្រឹមចិញ្ចើមខាងកើតតិរិវិថីព្រះស៊ីសុវត្ថិ ទល់មាត់ទឹក ចាប់ពីរបងខាងជើងស្ថានីយស្តុកប្រេងឥន្ធនៈសូតិម៉ិច ឫស្សីកែវ ត្រឹមខ្សែស្របរយៈទទឹងខាងជើង ១២៨៣០០០ មកខាងត្បូងរហូតដល់ព្រះតម្លង់ ខាងមុខវត្តឧណ្ណាលោម ។

ខ-ផ្នែកជ្រោយចង្វារ : ចាប់ពីមាត់ច្រាំងរហូតដល់មាត់ទឹក ពីភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ខ្សែស្របរយៈទទឹងខាងជើង ១២៨៤០០០ រហូតដល់ភូមិកណ្តាល ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ខ្សែរយៈបណ្តោយខាងកើត ៤៩៧០០០ ។

**តំបន់ទី២ : ទន្លេមេគង្គលើ ( ចតុមុខ-ទន្លេបិទ )**

ចាប់ពីចំណុចចុងកោះឧញ៉ាតី ខ្សែស្របរយៈទទឹងខាងជើង ១២៨៤០០០ (PK 353+800) រហូតដល់ទន្លេបិទ ខ្សែស្របរយៈទទឹងខាងជើង ១៣២៨៦០០ (PK 447) ។

**តំបន់ទី៣: ទន្លេមេគង្គក្រោម ( ចតុមុខ-អ្នកលឿង )**

ចាប់ពីភូមិវាលស្បូវ ខ្សែរយៈបណ្តោយខាងកើត ៤៩៧០០០ (PK 344+600) រហូតដល់អ្នកលឿង ខ្សែស្របរយៈទទឹងខាងជើង ១២៤៣៣០០ (PK 292) ។

ផែនទីកំណត់ព្រំប្រទល់ការគ្រប់គ្រងមណ្ឌលអាជីវកម្មផែភ្នំពេញ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រងមណ្ឌលអាជីវកម្មផែភ្នំពេញ

**មាត្រា ៣:—**

មណ្ឌលអាជីវកម្មផែភ្នំពេញ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់កំពង់ផែស្វយ័តភ្នំពេញ។

**មាត្រា ៤:—**

ហេដ្ឋារចនាសម្ព័ន្ធផែ ដែលមាននៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តភ្នំពេញ។

ដោយឡែក ទ្រព្យសម្បត្តិរបស់រដ្ឋដទៃទៀត ដែលស្ថិតនៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ជាសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន រាជធានី និងខេត្តសាមី។

**មាត្រា ៥:—**

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផែ ក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ត្រូវមានការឯកភាពពីកំពង់ផែស្វយ័តភ្នំពេញ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៦:—**

ការងារអាជីវកម្ម និងការគ្រប់គ្រងមណ្ឌលអាជីវកម្មផ្សេងៗកន្លងមក ដែលស្ថិតនៅក្នុងក្របខណ្ឌ នៃអនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៦ ត្រូវបន្តសុពលភាពស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៧:—**

អនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៦ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។៚

**មាត្រា ៨:_**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន អភិបាលរាជធានីភ្នំពេញ និងខេត្តពាក់ព័ន្ធ ព្រមទាំងកំពង់ផែស្វយ័តភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

ឧបសម្ព័ន្ធ
អនុក្រឹត្យលេខ ០៦ អនក្រ.បក
ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៩
ស្តីពីការបង្កើតមណ្ឌលអាជីវកម្មដីភ្នំពេញ




| ភ្នំពេញ - ក្អមសំណរ | |
|---|---|
| 1- ចតុមុខ | L=10,000m ,D=-15m |
| 3- ជ្រោយអំពិល | L=1,280m , D=-15m |
| 5- កោះធ្លាក់ | L=12,000m ,D=-10m |
| 7- កោះកែវ | L=4,600m , D=-15m |
| 9- ព្រែកដាច់ | L=3,100m , D=-15m |
| 11- ពាមរាំង | L=3,600m , D=-15m |

| ភ្នំពេញ - កំពង់ចាម | |
|---|---|
| 2- កោះដាច់ | L=11,000m ,D=-10m |
| 4- ស្វាឯក | L=11,000m ,D=-10m |
| 6- ស្ពៅ | L=8,000m , D=-5m |
| 8- ព្រែកពោធិ៍ | L=3,100m , D=-5m |
| 10- កំពង់ចាម | L=15,000m , D=-5m |

បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី ៣០ ខែ ១២ ឆ្នាំ ២០០៨
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
ប្រធានអគ្គនាយក

ហ៊ុំ ធារី

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងការិយាល័យអាជីវកម្មរ៉ែ និងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែ ទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សម្រេច

**មាត្រា១ :** ដំឡើងការិយាល័យអាជីវកម្មរ៉ែ និងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា២ :** នាយកដ្ឋានរ៉ែសំណង់ មានតួនាទី និងភារកិច្ច ដូចតទៅ :

- រៀបចំគោលការណ៍នានាដែលទាក់ទងដល់ការស្វែងរុករក និងការធ្វើអាជីវកម្មរ៉ែសំណង់ ដែលមានជាអាទិ៍ : ថ្មអារ ថ្មសំណង់ ក្រួស ខ្សាច់សំណង់ ដីឥដ្ឋសំណង់ ឡាតេរីត និងអាចម៍ដី ។

- សិក្សា វិភាគ និងវាយតម្លៃសក្តានុពលធនធានរ៉ែសំណង់ លើផ្នែកបរិមាណ គុណភាព និង សេដ្ឋកិច្ច ។
- ត្រួតពិនិត្យ និងគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែសំណង់ ។
- រៀបចំស្ថិតិផលិតកម្ម-អាជីវកម្មធនធានរ៉ែសំណង់ ។
- គ្រប់គ្រង ត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន ការស្តារបរិស្ថាន និងសុវត្ថិភាពពលកម្ម ។
- សហការ/ពិនិត្យផ្តល់មតិលើផ្នែកបច្ចេកទេសអាជីវកម្ម ឬជីកយក និង វាយតម្លៃរបាយការណ៍ បច្ចេកទេសរបស់ក្រុមហ៊ុន/ សម្បទានិក ។
- គ្រប់គ្រង ណែនាំ ពិនិត្យ និងតាមដានការអនុវត្តន៍ច្បាប់ អនុក្រឹត្យ បទប្បញ្ញត្តិ និង បទបញ្ជានានា។
- លើកគំរោង អនុវត្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ។

**មាត្រា៣ :** នាយកដ្ឋានរ៉ែសំណង់ ដឹកនាំដោយប្រធាន ០១ រូប និង អនុប្រធានមួយចំនួនជាជំនួយការតាម ការចាំបាច់។

**មាត្រា៤ :** រចនាសម្ព័ន្ធព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានរ៉ែសំណង់ ត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**មាត្រា៥ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ស៊ុយ សែម**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១.អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**ស ម្រេ ច**

**មាត្រា ១.-**

តែងតាំងជំនួយការឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើប្រធាននាយកដ្ឋានដូចមានរាយនាមខាងក្រោម :

១- លោក **សៀក វិចិត្រ**

២- លោក **សុទ្ធ គីមកុលមុនី**

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី , គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ , រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី, រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧ អនក្រ.តត

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន០៨រូប ជាសមាជិកគណៈកម្មការចំរុះខណ្ឌទាំង៧ ក្នុងរាជធានីភ្នំពេញ ដែលមានស្នាដៃល្អក្នុងការចុះត្រួតពិនិត្យនិងចាត់វិធានការទប់ស្កាត់សកម្មភាពជួញដូរស្នាដៃភាពយន្ត-ស្នាដៃវីដេអូខុសច្បាប់និងអាសអាភាស ដូចមានរាយនាមខាងក្រោម :-

១- លោក **ឈិន សុខ** ប្រធានការិយាល័យវប្បធម៌ ខណ្ឌទួលគោក

២- លោក **ព្រុំ សុផាណ្ណា** ប្រធានការិយាល័យវប្បធម៌ ខណ្ឌមានជ័យ

៣- លោក **ចិន សំបូរ** ប្រធានការិយាល័យវប្បធម៌ ខណ្ឌដង្កោ

៤- លោក **ជា សោភ័ណ** អនុប្រធានការិយាល័យវប្បធម៌ ខណ្ឌ ៧ មករា

៥- លោក **សៅ ផាន** អនុប្រធានការិយាល័យវប្បធម៌ ខណ្ឌ ដូនពេញ

៦- លោក **ទេត ទុង** អនុប្រធានការិយាល័យវប្បធម៌ ខណ្ឌ ចំការមន

៧- លោក **ស្រ៊ុន ម៉េងហ៊ង** អនុប្រធានការិយាល័យវប្បធម៌ ខណ្ឌ ឬស្សីកែវ

៨- លោក **កែម ធារ៉ា** អនុប្រធានការិយាល័យវប្បធម៌ ខណ្ឌទួលគោក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ហើយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហានចំណុះយោធភូមិភាគទី៥ និងតំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ ចំនួន ១១៤ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ឯក | គង់ | ឆេងចន | ០០២៨១៧ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ២-វរសេនីយ៍ទោ | ព្រាំ | សារ៉ុន | ០០០៩៥៥ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៣-វរសេនីយ៍ទោ | សុខ | រ៉ិដ្ឋល | ០០០៩៥៦ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៤-វរសេនីយ៍ទោ | រស់ | ធៀត | ០០០៩៥៧ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៥-វរសេនីយ៍ទោ | ជា | ផាន | ០០២១៧៣ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៦-វរសេនីយ៍ទោ | អ៊ុក | វណ្ណា | ០០៤៩៦៧ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៧-វរសេនីយ៍ទោ | ឃី | នឹម | ០១៥៩២១ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៨-វរសេនីយ៍ទោ | រស់ | ឬទ្ធី | ០១០៤៨៦ | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៩-វរសេនីយ៍ទោ | សុខ | សាគល | ០០២៨៣២ | មេបញ្ជាការរង និងជានាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ១០-វរសេនីយ៍ទោ | គង់ | ធី | ០១០១៧២ | នាយរងការិ.បច្ចេកទេស នាយកដ្ឋានប្រេងឥន្ធនៈ ក្រ.ស ការពារជាតិ |
| ១១-វរសេនីយ៍ទោ | អ៊ុក | សន្ធា | ០១៥៧៧០ | នាយឯកទេសវិស្វកម្ម យោធភូមិភាគ ទី៥ |
| ១២-វរសេនីយ៍ទោ | សួន | ពិសិដ្ឋ | ០០២៦០២ | នាយរងការិយាល័យ ទី៣ យោធភូមិភាគ ទី៥ |

| | | | | |
|---|---|---|---|---|
| ១៣-វរសេនីយ៍ត្រី | ហ៊ួរ | អ៊ុត | ០១៥៥១៥ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១៤-វរសេនីយ៍ត្រី | ទឹម | យ៉ុន | ០១០៤៩១ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១៥-វរសេនីយ៍ត្រី | ម៉ែន | យ៉ុន | ០១០៤៩២ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១៦-វរសេនីយ៍ត្រី | សាញ់ | សុក្រឹត្យ | ០១៥៥១៦ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១៧-វរសេនីយ៍ត្រី | សាទិន | ទិមុល | ០១៥៥១៨ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១៨-វរសេនីយ៍ត្រី | ឃួន | សំបូរ | ០២៩០៧០ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១៩-វរសេនីយ៍ត្រី | នួន | សុផុន | ០២៩០៦៤ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២០-វរសេនីយ៍ត្រី | ជួប | ឡឺយ | ០១០៤៩៣ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២១-វរសេនីយ៍ត្រី | កៅ | ឡាយ | ០១០៤៩០ | នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២២-វរសេនីយ៍ត្រី | សាន | យ៉ាផានិត | ០២៩០១១ | នាយលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៣-វរសេនីយ៍ត្រី | ឆេព | ប៊ុខ | ០១៥៥២៩ | នាយផ្នែកហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៤-វរសេនីយ៍ត្រី | ស្វាយ | គង់ | ១៩៧៨៩៣ | នាយការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៥-វរសេនីយ៍ត្រី | រស់ | តេខ | ០២៩០១៤ | នាយការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៦-វរសេនីយ៍ត្រី | សាន់ | ស៊ី | ១៩៧៨៩៣ | នាយការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៧-វរសេនីយ៍ត្រី | នុត | នាខ | ០១៥៥២៣ | នាយការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៨-វរសេនីយ៍ត្រី | ឆក | សេខ | ០១៥៥២៥ | នាយការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៩-វរសេនីយ៍ត្រី | ខ៊ាន់ | សំណាខ | ០១២៩៥៣ | នាយការិ.ជីវពល តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣០-វរសេនីយ៍ត្រី | ឌឿ | សាឌុង | ០១៥៥៣៥ | នាយការិ.ហ្វឹកហ្វឺន តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣១-វរសេនីយ៍ត្រី | នេន | ញាណ | ០២៩០៦៩ | មេបញ្ជាការវរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣២-វរសេនីយ៍ត្រី | ថ្វាំ | អ៊ុន | ០១៥៥៣៧ | មេបញ្ជាការផ្នែកសឹករងខណ្ឌព្រៃនប់ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣៣-វរសេនីយ៍ត្រី | ឃុន | ឡា | ០២៩០២២ | មេបញ្ជាការផ្នែកសឹករងខណ្ឌស្ទឹងហាវ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣៤-វរសេនីយ៍ត្រី | សុខ | សុគំភ្រា | ០១៥៥៣ | មេបញ្ជាការផ្នែកសឹករងខណ្ឌមិត្តភាព តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣៥-វរសេនីយ៍ត្រី | ឌុល | សុគំណូ | ០០៥១០៨ | នាយរងឯកទេសវិស្វកម្ម យោធភូមិភាគទី៥ |
| ៣៦-វរសេនីយ៍ត្រី | សយ | វណ្ណសក្តិ | ០៤២០១០ | នាយផ្នែកប្រេង ការិ.៤ យោធភូមិភាគទី៥ |
| ៣៧-វរសេនីយ៍ត្រី | ចាន់ | ថុលឡា | ០១០៦២៦ | នាយផ្នែកស្បៀង ការិ.៤ យោធភូមិភាគទី៥ |
| ៣៨-វរសេនីយ៍ត្រី | ថុយ | ទ្រី | ០១០៦៤០ | នាយផ្នែកព័ត៌មាន ការិ.៥ យោធភូមិភាគទី៥ |
| ៣៩-វរសេនីយ៍ត្រី | យ៉ែម | សារឿន | ០២៣០១៣ | នាយរង ការិ.ហិរញ្ញវត្ថុ យោធភូមិភាគទី៥ |
| ៤០-អនុសេនីយ៍ឯក | អ៊ុក | ចាន់ណារិទ្ធ | ០២៩០៥៧ | នាយរងការិ.ទី១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៤១-អនុសេនីយ៍ឯក | ឃិន | ហាន | ០២៩០១៣ | នាយរងការិ.ទី១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៤២-អនុសេនីយ៍ឯក | រស់ | សារិទ្ធ | ០១៥៧៨២ | នាយផ្នែកបុគ្គលិក ការិ.ទី១ យោធភូមិភាគទី៥ |
| ៤៣-អនុសេនីយ៍ឯក | ស៊ឹម | ទិសេស | ០១៥៧៨០ | នាយផ្នែកតែងតាំង ការិ.ទី១ យោធភូមិភាគទី៥ |
| ៤៤-អនុសេនីយ៍ឯក | ប៊ុត | ប៊ុនធឿន | ០១៥៨៩២ | ជំនួយការបុគ្គលិក ការិ.ទី១ យោធភូមិភាគទី៥ |
| ៤៥-អនុសេនីយ៍ឯក | ប៊ុន | សុខឿន | ០១១៩៩៧ | នាយផ្នែកបរិក្ខា ការិ.៤ យោធភូមិភាគទី៥ |
| ៤៦-អនុសេនីយ៍ឯក | ប៊ុន | ដារ៉ា | ០៩១០១៤ | នាយរងឯកទេសការពារអាកាស យោធភូមិភាគទី៥ |
| ៤៧-អនុសេនីយ៍ឯក | ម៉ន | អាត | ០៣០១៨៤ | ជំនួយការឯកទេសវិស្វកម្ម យោធភូមិភាគទី ៥ |
| ៤៨-អនុសេនីយ៍ឯក | ឡាច | សុធី | ០៣០១៨១ | ជំនួយការឯកទេសវិស្វកម្ម យោធភូមិភាគទី ៥ |
| ៤៩-អនុសេនីយ៍ឯក | ឆាយ | គឹមហួរ | ០១៩៥២៥ | ជំនួយការឯកទេសវិស្វកម្ម យោធភូមិភាគទី ៥ |

| | | | | |
|---|---|---|---|---|
| ៥០-អនុសេនីយ៍ឯក | នួន | ធី | ០២៣០៧៩ | នាយផ្នែកហ្វឹកហ្វឺន កា.វិ.យោធាតំបន់យោធភូមិភាគទី ៥ |
| ៥១-អនុសេនីយ៍ឯក | ឡុញ | សំ | ០៤១៩៦៨ | ជំនួយការ ការិយាល័យទី៤ យោធភូមិភាគទី ៥ |
| ៥២-អនុសេនីយ៍ឯក | យឹម | ជាម៉ុនធឿន | ០១៩៤១០ | ជំនួយការ ការិយាល័យទី២ យោធភូមិភាគទី ៥ |

**ខ-មេបញ្ជាការរងអនុសេនីយ៍ឯក**

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ត្រី | សោ | ម៉ុនហូ | ០២២២៥៨ | នាយផ្នែកដឹកជញ្ជូន កា.វិទី ៤ យោធភូមិភាគទី ៥ |
| ២-អនុសេនីយ៍ឯក | សួន | សុខណា | ០១៥៥៣៤ | នាយកា.វិ.អភិវឌ្ឍន៍តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៣-អនុសេនីយ៍ឯក | អ៊ូច | សុតិន | ០២៩០៤២ | នាយរងកា.វិ.ទី២ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៤-អនុសេនីយ៍ឯក | ណុប | ផង់ | ០២៩០៣៨ | នាយរងកា.វិ.ទី៤ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៥-អនុសេនីយ៍ឯក | ម៉ុន | សឿន | ០១៥៥០៩ | មេបញ្ជាការរងវរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៦-អនុសេនីយ៍ឯក | ពេត | ម៉ូ | ០១៥៥៣២ | មេបញ្ជាការរងផ្នែកសឹករងខណ្ឌព្រៃនប់ តំបន់ប្រតិបត្តិការ សឹករង ក្រុងព្រះសីហនុ |
| ៧-អនុសេនីយ៍ឯក | ស៊ុន | ម៉ៅ | ០២៩០៦៨ | មេបញ្ជាការរងផ្នែកសឹករងខណ្ឌព្រៃនប់ តំបន់ប្រតិបត្តិការ សឹករង ក្រុងព្រះសីហនុ |
| ៨-អនុសេនីយ៍ឯក | កែវ | ម៉ើត | ០២៩០២១ | មេបញ្ជាការរងផ្នែកសឹករងខណ្ឌមិត្តភាព តំបន់ប្រតិបត្តិការ សឹករង ក្រុងព្រះសីហនុ |
| ៩-អនុសេនីយ៍ឯក | រស់ | ហឿន | ១៥៧៧៨១ | មេបញ្ជាការរងផ្នែកសឹករងខណ្ឌមិត្តភាព តំបន់ប្រតិបត្តិការ សឹករង ក្រុងព្រះសីហនុ |
| ១០-អនុសេនីយ៍ឯក | ម៉ក់ | សារឹម | ០៤១៤០៥ | មេបញ្ជាការរង វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១១-អនុសេនីយ៍ឯក | យឹម | ឧត្តម | ០៣៥២២៨ | ជំនួយការការិយាល័យ ទី៤ យោធភូមិភាគទី ៥ |
| ១២-អនុសេនីយ៍ឯក | ឌួច | ហាក់ | ០៧៣២២៤ | ជំនួយការការិយាល័យ ទី៤ យោធភូមិភាគទី ៥ |
| ១៣-អនុសេនីយ៍ឯក | ឡុង | ម៉ុនសេង | ០៣០២០៩ | ជំនួយការការិយាល័យ ទី៤ យោធភូមិភាគទី ៥ |
| ១៤-អនុសេនីយ៍ឯក | អ៊ុន | សុធី | ០២៣២៤៨ | ជំនួយការការិយាល័យ ទី៣ យោធភូមិភាគទី ៥ |
| ១៥-អនុសេនីយ៍ឯក | ហ៊ុង | គីរីរដ្ឋ | ០១២២៤៣ | ជំនួយការការិយាល័យ ទី៣ យោធភូមិភាគទី ៥ |
| ១៦-អនុសេនីយ៍ឯក | ចៅ | សំ | ១៦១២៧៦ | ជំនួយការឯកទេសបញ្ជូនសារ យោធភូមិភាគទី ៥ |
| ១៧-អនុសេនីយ៍ឯក | ស៊ុម | សុគន្ធ | ០២៣០១៥ | ជំនួយការការិយាល័យ ទី២ យោធភូមិភាគទី ៥ |
| ១៨-អនុសេនីយ៍ឯក | គ្រី | ម៉ុនធឿន | ០៤២០១៦ | ជំនួយការការិយាល័យ ទី២ យោធភូមិភាគទី ៥ |
| ១៩-អនុសេនីយ៍ឯក | ជា | សៅឌី | ០៦៩៨៩៨ | ជំនួយការការិយាល័យ ទី២ យោធភូមិភាគទី ៥ |
| ២០-អនុសេនីយ៍ឯក | ហត្ថ | ធី | ០១៦៥៦០ | ជំនួយការការិយាល័យ ទី២ យោធភូមិភាគទី ៥ |
| ២១-អនុសេនីយ៍ឯក | មៀច | អឿន | ០២២២០២ | ជំនួយការការិយាល័យ ទី៣ យោធភូមិភាគទី ៥ |
| ២២-អនុសេនីយ៍ទោ | ពេជ្រ | សារី | ០៣៥២១៦ | ជំនួយការការិយាល័យ ទី២ យោធភូមិភាគទី ៥ |
| ២៣-អនុសេនីយ៍ទោ | ហាក់ | សុជាតិ | ០៣៥៦៧៤ | ជំនួយការការិយាល័យ ទី២ យោធភូមិភាគទី ៥ |
| ២៤-អនុសេនីយ៍ទោ | សូ | សារិន | ០១៥៥២៧ | នាយរងលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៥-អនុសេនីយ៍ទោ | ឃុត | សុធន់ | ១៥៧៧៦៦ | នាយរងកា.វិ.ទី ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៦-អនុសេនីយ៍ទោ | ឡុង | មុន្នី | ១៥៨១៨១ | នាយរងកា.វិ.ទី ២ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៧-អនុសេនីយ៍ទោ | ខែម | ហ៊ុល | ០២៩០២៣ | នាយរងកា.វិ.ទី ៣ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៨-អនុសេនីយ៍ទោ | អ៊ុក | ស៊ីណែ | ០២៩០២៧ | នាយរងកា.វិ. ទី៤ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៩-អនុសេនីយ៍ទោ | សម | សុធី | ០២៩០២០ | នាយផ្នែកវិស្វកម្ម តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣០-អនុសេនីយ៍ទោ | សំ | ចាន់ម៉ារ៉ា | ០២៩០៦៦ | នាយផ្នែកគិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣១-អនុសេនីយ៍ត្រី | ណុច | ខេន | ០៤២០៣៧ | ជំនួយការការិយាល័យ ទី២ យោធភូមិភាគទី ៥ |

| | | | | |
|---|---|---|---|---|
| ៣២-នាយចំណង់ | យស់ | ណារ៉ាត់ | ១០៨៦៨៧ | ជំនួយការការិយាល័យ ទី៤ យោធភូមិភាគទី ៥ |
| ៣៣-នាយចំណង់ | ម៉េង | ហុង | ១០៨៧៧៦ | ជំនួយការការិយាល័យ ទី៤ យោធភូមិភាគទី ៥ |
| ៣៤-នាយចំណង់ | ចំរើន | រិទ្ធ | ០៤២២០៦ | ជំនួយការការិយាល័យ ទី៤ យោធភូមិភាគទី ៥ |

**គ_មេដាយសិរីវឌ្ឍនការងារ :**

| | | | | |
|---|---|---|---|---|
| ១-អនុសេនីយ៍ទោ | លឹម | ប៊ូ | ១៥៧៧៩៤ | នាយផ្នែកបច្ចេកទេស តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២-អនុសេនីយ៍ទោ | ប៊ុន | ណារិន | ១៥៧៧៩០ | ជំនួយការស្បៀង តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៣-អនុសេនីយ៍ទោ | ស៊ុន | ធឿន | ០៦៥២២០ | ជំនួយការជីវពល តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៤-អនុសេនីយ៍ទោ | ម៉ែត | គួ | ១៥៧៨៦១ | ជំនួយការបុគ្គលិក តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៥-នាយចំណង់ | ទ្រាប | សារឿន | ១៥៧៨២៨ | មេបញ្ជាការរង អ.ធំ១ វ.ត ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៦-នាយចំណង់ | ម៉ែន | ឌុល | ១៥៧៨៦៦ | មេបញ្ជាការរង អ.ធំ២ វ.ត ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៧-នាយចំណង់ | ណារ | ប្រុស | ០៤១៤០៧ | មេបញ្ជាការរង អ.ធំ៣ វ.ត ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ៨-ព្រិន្ទបាលឯក | នួន | គឿង | ១៥៧៨២០ | ជំនួយការវិទ្យុទាក់ទង វ.ត ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះ សីហនុ |
| ៩-ព្រិន្ទបាលឯក | សាញ់ | សាទី | ២០៧០០៨ | មេបញ្ជាការរង អ.ត ៣ អ.ធំ៣ វ.ត១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ១០-ព្រិន្ទបាលឯក | លន់ | ពៅល | ០៦៥១៩១ | មេបញ្ជាការរង អ.ត៣ អ.ធំ៣ វ.ត១ តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១១-ព្រិន្ទបាលឯក | និត្យ | មួន | ១៥៧៨៦៨ | មេបញ្ជាការរង អ.ត២ អ.ធំ៣ វ.ត១ តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១២-ព្រិន្ទបាលឯក | សាគល | សុជាតិ | ១៤១១០១ | ជំនួយការប្រេង ការិ.ទី៤ តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១៣-ព្រិន្ទបាលឯក | គង់ | ចាន់ដារ៉ា | ១៥៧៨០៩ | ជំនួយការហ្វឹកហ្វឺនផ្នែកសឹករងខណ្ឌមិត្តភាព តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១៤-ព្រិន្ទបាលឯក | យ៉ាន់ | ឫទ្ធី | ១៥៧៨៧០ | ជំនួយការចិត្តសាស្ត្រផ្នែកសឹករងខណ្ឌមិត្តភាព តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១៥-ព្រិន្ទបាលឯក | មុំ | ថារ៉ា | ០៦៥២០៩ | ជំនួយការចិត្តសាស្ត្រផ្នែកសឹករងខណ្ឌស្ទឹងហាវ តំបន់ប្រតិបត្តិការ សឹករង ក្រុងព្រះសីហនុ |
| ១៦-ព្រិន្ទបាលឯក | សរ | សារី | ២០៦៨៥១ | យុទ្ធជនបញ្ជូនសារ តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១៧-ព្រិន្ទបាលឯក | កែវ | ថុល | ២០៦៨២៤ | ជំនួយការហ្វឹកហ្វឺនផ្នែកសឹករងខណ្ឌព្រៃនប់ តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១៨-ព្រិន្ទបាលឯក | មាន | សៀងហៃ | ១៥៧៨៥៧ | ជំនួយការចិត្តសាស្ត្រផ្នែកសឹករងខណ្ឌព្រៃនប់ តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ១៩-ព្រិន្ទបាលឯក | ឡោះ | រី | ០៩៣៤៩០ | មេរងក្រុម វរសេនាតូច លេខ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២០-ព្រិន្ទបាលឯក | ចៅ | ចាន់ណាត | ២០៧០១១ | ជំនួយការហ្វឹកហ្វឺនផ្នែកសឹករងខណ្ឌព្រៃនប់ តំបន់ប្រតិបត្តិការសឹក រង ក្រុងព្រះសីហនុ |
| ២១-ព្រិន្ទបាលទោ | អ៊ុក | សុវណ្ណារិទ្ធ | ១៨៧២៤៣ | មេបញ្ជាការ អនុសេនាតូចលេខ១ អនុសេនាធំលេខ១ វរសេនាតូច ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២២-ព្រិន្ទបាលទោ | សាំង | គឹមហេង | ១៤១១០០ | ជំនួយការបញ្ជូនសារ អនុសេនាធំ៣ វរសេនាតូចលេខ ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៣-ព្រិន្ទបាលទោ | ហឿង | អូម៉ា | ១៤១១០៩ | មេក្រុមទី៣ វរសេនាតូច លេខ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |

| | | | | |
|---|---|---|---|---|
| ២៤-ពលបាលឯក | កែវ | សុធា | ២០៦៨១៩ | បុគ្គលិកបំរើការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៥-ពលបាលឯក | ទ្រាំ | តេន | ១៨៧២៦៧ | មេក្រុម ១ អនុសេនាតូចលេខ៣ អនុសេនាធំលេខ១ វ.ត ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៦-ពលបាលឯក | ហួត | ហាន | ០៩៣៥០១ | ជំនួយការចលនូប្ប ត្តម្ភ អ.ធ២ វ.ត១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៧-ពលបាលឯក | ខ្លិម | ប៊ុនសៀក | ២០៦៩៧៤ | បុគ្គលិកបំរើការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |
| ២៨-ពលបាលឯក | សុខ | សារឿន | ០៩៣៤៩៦ | អ្នកបាញ់កាំភ្លើង វ.ត១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការបញ្ចប់តំណែងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

### សម្រេច

**មាត្រា១:** ត្រូវបានបញ្ចប់តំណែងជំនួយការលោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីចំនួន០៤រូបដូចមានរាយនាមខាងក្រោម:

១- លោកស្រី **យូ សំអាន** មានឋានៈស្មើ អគ្គនាយករង

២- លោក **ណូស អ៊ីព្រាហ៊ីម** មានឋានៈស្មើ អគ្គនាយករង

៣- លោកស្រី **ស គន្ធា** មានឋានៈស្មើ អគ្គនាយករង

៤- លោក **គង់ ឈួន** មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PSSD-12/31/2008

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំនួន ១៨៩១ កន្លែង ( មួយពាន់ប្រាំបីរយកៅសិបមួយ ) ដល់ក្រសួងមហាផ្ទៃ សម្រាប់បំពេញតម្រូវការចាំបាច់នៃការងារការពារសន្តិសុខជាតិ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

**មាត្រា២ :** ក្របខ័ណ្ឌបន្ថែមថ្មីនេះ ត្រូវបានទទួលប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗរបស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ចាប់ពីខែ សីហា ឆ្នាំ ២០០៩ តទៅ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល :*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង ចំនួន៦២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | ម៉ែន | សុផល្លី | អនុប្រធាននាយកដ្ឋានទំនាក់ទំនងរាជរដ្ឋាភិបាលនិងរដ្ឋសភា-ព្រឹទ្ធសភា |
២០១-អនុសេនីយ៍ទោ សុខ ចាន់តារា
២០២-អនុសេនីយ៍ទោ នុច ជិបុល
២០៣-អនុសេនីយ៍ទោ យឹម ផេងលី
២០៤-អនុសេនីយ៍ទោ ស្រី សំណាង
២០៥-អនុសេនីយ៍ទោ ឈួន គីមលី
២០៦-អនុសេនីយ៍ទោ ឃួន សុគន្ធា

| | | | | | |
|---|---|---|---|---|---|
| ២០៧-អនុសេនីយ៍ទោ | ស៊ីម | សុចណ្ណារ៉ា | ២០៨-អនុសេនីយ៍ទោ | យូ | ថៃ |
| ២០៩-អនុសេនីយ៍ទោ | ថៃ | ណារិទ្ធ | ២១០-អនុសេនីយ៍ទោ | សេង | សោភ័ណ្ឌ |
| ២១១-អនុសេនីយ៍ទោ | យឿម | យ៉ី | ២១២-អនុសេនីយ៍ទោ | មនោ | សុជាតិ |
| ២១៣-អនុសេនីយ៍ទោ | ពេជ្រ | សាមាស | ២១៤-អនុសេនីយ៍ទោ | ស៊ូន | សារ៉េត |
| ២១៥-អនុសេនីយ៍ទោ | ព្រាំ | សុផល | ២១៦-អនុសេនីយ៍ទោ | យឹម | សុចណ្ណ |
| ២១៧-អនុសេនីយ៍ទោ | នង | ស៊ីធឿន | ២១៨-អនុសេនីយ៍ទោ | មាស | ផល្លី |
| ២១៩-អនុសេនីយ៍ទោ | ជៀប | តាំង | ២២០-អនុសេនីយ៍ទោ | ថាន់ | សុហេង |
| ២២១-អនុសេនីយ៍ទោ | ហាន់ | ណេង | ២២២-អនុសេនីយ៍ទោ | ឃួន | សំណាង |
| ២២៣-អនុសេនីយ៍ទោ | រ៉ម | រ៉ូមធី | ២២៤-អនុសេនីយ៍ត្រី | នូ | សុធី |
| ២២៥-អនុសេនីយ៍ទោ | សរ | សំអុល | ២២៦-អនុសេនីយ៍ត្រី | ភឿន | អន្ទមុន្នី |
| ២២៧-អនុសេនីយ៍ត្រី | ជី | ពិសិដ្ឋ | ២២៨-អនុសេនីយ៍ត្រី | ញឹម | បូរ៉ា |
| ២២៩-អនុសេនីយ៍ត្រី | តិន | សុធី | ២៣០-អនុសេនីយ៍ត្រី | ចន្ទ | សុភារ៉ា |
| ២៣១-អនុសេនីយ៍ត្រី | ឡៀង | ធូត | ២៣២-អនុសេនីយ៍ត្រី | ហៀម | យន |
| ២៣៣-អនុសេនីយ៍ត្រី | ហាត់ | ប៊ុនថាន់ | ២៣៤-អនុសេនីយ៍ត្រី | អ៊ួង | សុខា |
| ២៣៥-អនុសេនីយ៍ត្រី | ទឹម | រតនៈ | ២៣៦-អនុសេនីយ៍ត្រី | នួន | សុភ័ក្រ |
| ២៣៧-អនុសេនីយ៍ត្រី | និត្យ | សាថ៉ាតនី | ២៣៨-អនុសេនីយ៍ត្រី | សំ | លាត |
| ២៣៩-អនុសេនីយ៍ត្រី | តែច | ចាន់ធឿន | ២៤០-អនុសេនីយ៍ត្រី | សៅ | សឿត |
| ២៤១-អនុសេនីយ៍ត្រី | ឌិម | ម៉េងអឿង | ២៤២-អនុសេនីយ៍ត្រី | ប៊ុល | រ៉ាស៊ី |
| ២៤៣-អនុសេនីយ៍ត្រី | ឡៀង | សំអាង | ២៤៤-អនុសេនីយ៍ត្រី | ឡូច | ចំរើន |
| ២៤៥-អនុសេនីយ៍ត្រី | តាន់ | ភួន | ២៤៦-អនុសេនីយ៍ត្រី | ហែម | សំខាន់ |
| ២៤៧-អនុសេនីយ៍ត្រី | ហ៊ន | គីមហេង | ២៤៨-អនុសេនីយ៍ត្រី | សុខ | ស៊ីថា |
| ២៤៩-អនុសេនីយ៍ត្រី | ពិន | ពិដាន | ២៥០-អនុសេនីយ៍ត្រី | គង់ | ស៊ីណាត |
| ២៥១-អនុសេនីយ៍ត្រី | ហែម | ធឿន | ២៥២-អនុសេនីយ៍ត្រី | គង | ញាណមុន្នី |
| ២៥៣-អនុសេនីយ៍ត្រី | ទូច | សារិត | ២៥៤-អនុសេនីយ៍ត្រី | ឈិត | ណារឿន |
| ២៥៥- នាយសំណង់ | ផល្លា | ឡូចិនលី | ២៥៦-នាយសំណង់ | គឹម | បុទ្ធី |
| ២៥៧-នាយសំណង់ | ឆាយ | ភក្តី | ២៥៨-នាយសំណង់ | យូ | សុធារិទ្ធ |
| ២៥៩-នាយសំណង់ | ជឹម | ចាន់ដា | ២៦០-នាយសំណង់ | ហួ | សារឿន |
| ២៦១-នាយសំណង់ | សយ | ពើម | ២៦២-នាយសំណង់ | ម៉ែន | មុន្នី |
| ២៦៣-នាយសំណង់ | ចាន់ | សដារ៉ា | ២៦៤-នាយសំណង់ | ហ៊ន | ខ្សៃគង |
| ២៦៥-អនុសេនីយ៍ត្រី | យឹម | ឈន | ២៦៦-អនុសេនីយ៍ត្រី | គ្រី | ផារី |
| ២៦៧-ព្រិន្ទបាលឯក | យីច | ជា | ២៦៨-ព្រិន្ទបាលឯក | ដួង | សាចន្ទ |
| ២៦៩-ព្រិន្ទបាលឯក | សុខ | ថៃ | ២៧០-ព្រិន្ទបាលឯក | គង់ | ផុន |
| ២៧១-ព្រិន្ទបាលឯក | ទឹន | សារុន | ២៧២-ពលបាលឯក | ណន | នឹម |
| ២៧៣-ពលបាលឯក | សុខ | សារុន | ២៧៤-ពលបាលឯក | គឹម | គីរី |
| ២៧៥-ពលបាលឯក | ឡុង | ចាន់ថន | ២៧៦-ពលបាលឯក | ស្លួង | ប្រុស |
| ២៧៧-ពលបាលឯក | ហួង | ភា | ២៧៨-ពលបាលឯក | យឿ | លី |

២៧៩-លោក អ៊ិុច សុនា

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩. អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការជូន គ្រឿងឥស្សរិយយស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- យោងតាមសំណើរបស់ សម្ដេចចៅហ្វាវាំង **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

## សម្រេច

**មាត្រា ១ :** បំពាក់ គ្រឿងឥស្សរិយយស តាមប្រភេទ និង លំដាប់ថ្នាក់ ជូន ក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ដែលបានធ្វើស្ដង់ពិព័រណ៍ ផលិតផលកសិកម្ម កសិ-ឧស្សាហកម្ម ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ដូចខាងក្រោម :

**ក-** គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **សេនា** :

**១-សាលាក្រុងភ្នំពេញ**
**២-ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ**
**៣-សាលាខេត្តកំពង់ចាម**
**៤-សាលាខេត្តកំពង់ឆ្នាំង**
**៥-ក្រសួងទេសចរណ៍**
**៦-ក្រសួងធនធានទឹក និងឧតុនិយម**
**៧-ក្រសួងបរិស្ថាន**

ខ. គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** :

១-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
២-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
៣-សាលាខេត្តតាកែវ
៤-សាលាខេត្តកណ្ដាល
៥-ក្រសួងពាណិជ្ជកម្ម
៦-សាលាខេត្តសៀមរាប
៧-សាលាខេត្តរតនគិរី
៨-ក្រសួងសាធារណការ និងដឹកជញ្ជូន
៩-សាលាខេត្តបាត់ដំបង

**គ. មេដាយមាសការងារ :**

១-សាលាខេត្តកំពង់ស្ពឺ
២-សាលាខេត្តកំពង់ធំ
៣-សាលាខេត្តប៉ៃលិន
៤-សាលាខេត្តស្វាយរៀង
៥-សាលាខេត្តកំពត
៦-សាលាខេត្តព្រៃវែង
៧-សាលាខេត្តមណ្ឌលគិរី
៨-សាលាខេត្តបន្ទាយមានជ័យ
៩-សាលាខេត្តព្រះសីហនុ
១០-សាលាខេត្តក្រចេះ
១១-សាលាខេត្តស្ទឹងត្រែង

**ឃ. មេដាយប្រាក់ការងារ :**

១-សាលាខេត្តឧត្ដរមានជ័យ
២-សាលាខេត្តពោធិ៍សាត់
៣-សាលាខេត្តកោះកុង
៤-សាលាខេត្តព្រះវិហារ
៥-សាលាខេត្តកែប

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា ១ :** ប្រគល់ភារកិច្ចជូនលោកស្រី **ឌេម សិខាមណី** ឱ្យបំពេញមុខងារជាអធិការ នៃអគ្គាធិការដ្ឋាន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩*

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧១...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/00៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមតម្រូវការការងារចាំបាច់

## សំរេច

**មាត្រា ១ :** តែងតាំងលោក ម៉ៅ សំអឿន ជាទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៩*

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧២..អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយករង ដូចមានរាយនាមខាងក្រោម :

១- លោក ឆ្នួម សេងហួរ

២- លោក គីម សុខ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា ១:** តែងតាំងលោកស្រី **នូ ដាវី** ជាទីប្រឹក្សាក្រសួងកិច្ចការនារី មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៩

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន នៅរាជធានីភ្នំពេញ ចំនួន ១៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការកសាងសមិទ្ធិផលនានា ដូចជាអគារសិក្សា ព្រះវិហារ របងវត្ត ស្រះទឹក សាលាឆាន់ កុដិ នៅក្នុងវត្តមង្គលមានលក្ខណ៍ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោក | **ងួន ប៊ុនសូ** | ថវិកាចំនួន | ១១.០០០ ដុល្លារ |
| ២- លោកមេធាវី | **ថូ ចាន់ធីរ៉ា** | ថវិកាចំនួន | ១០.៥០០ ដុល្លារ |
| ៣- លោកមេធាវី | **ជុន វាសនា** | ថវិកាចំនួន | ១០.៥០០ ដុល្លារ |
| ៤- លោកមេធាវី | **សួង យុនវិរៈបុត្រ** | ថវិកាចំនួន | ១០.៥០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៥- លោកមេធាវី | ម៉ុម ពិសី | ថវិកាចំនួន | ១០.៤០០ ដុល្លារ |
| ៦- លោក | អ៊ឹង សុភារិទ្ធ | ថវិកាចំនួន | ១០.៣០០ ដុល្លារ |
| ៧- លោក | ហាវ ស្រេង | ថវិកាចំនួន | ១០.២០០ ដុល្លារ |
| ៨- លោក | គីម ចំន្នរស្មី | ថវិកាចំនួន | ១០.២០០ ដុល្លារ |
| ៩- លោក | សំ ថន | ថវិកាចំនួន | ១០.២០០ ដុល្លារ |
| ១០- លោក | ឡាយ ញ៉ែម | ថវិកាចំនួន | ១០.១០០ ដុល្លារ |
| ១១- លោក | សំ លក្ខិណា | ថវិកាចំនួន | ១០.១០០ ដុល្លារ |
| ១២- លោក | អ៊ុត អ៉ារិន | ថវិកាចំនួន | ១០.១០០ ដុល្លារ |
| ១៣- លោកវរសេនីយ៍ឯក | វ៉ែម សារ៉ាត | ថវិកាចំនួន | ១០.០៩០ ដុល្លារ |
| ១៤- លោក | សួន វ៉ាស៊ី | ថវិកាចំនួន | ១០.០៨០ ដុល្លារ |
| ១៥- លោក | កែន ស៊ីថាន | ថវិកាចំនួន | ១០.០៥០ ដុល្លារ |
| ១៦- លោកវេជ្ជបណ្ឌិត | សៀង ឫទ្ធី | ថវិកាចំនួន | ១០.០៥០ ដុល្លារ |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និងប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមការចាំបាច់

### សម្រេច

**មាត្រា ១ :** តែងតាំងលោក ស៊ាង លាប ជាទីប្រឹក្សាក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២៦ អនក្រ.តត**

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់

## សម្រេច

**មាត្រា ១ :** តែងតាំងលោក ស៊ុត នីរ៉ាន់ ជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានឋានៈស្មើអគ្គនាយករង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ... ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ [illegible] អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមការចាំបាច់

### សម្រេច

**មាត្រា ១ :** តែងតាំងលោក វ៉ាត វ័ន្ត ជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើអគ្គនាយករង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៨ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ហួត យាងទេង** អត្តលេខ ០១៥១៨ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៩*
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ* ✓

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**មាត្រា ១ :** តែងតាំងលោក សុខ ឃន ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ០១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈករណីស្រាវជ្រាវស៊ើបអង្កេត ការកសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

ប្រការ ១ : ត្រូវបានបង្កើតគណៈករណីស្រាវជ្រាវស៊ើបអង្កេត ការកសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ សារិទ្ធ ហ៊ីន | ប្រធាន ក២ កងទ័ពជើងគោក | សមាជិក |

ប្រការ ២ : គណៈករណីនេះមានភារកិច្ច :

-ពិនិត្យ ស្រាវជ្រាវ ស៊ើបអង្កេត រាល់សកម្មភាព កសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ ដែលមានជនល្មើសឈ្មោះ សោម ឯក ជាមេក្លោង ។

-ប្រមែប្រមូលឯកសារ វត្ថុតាងផ្សេងៗ ទាក់ទងដល់សកម្មភាពខាងលើ

-ធ្វើការប្រជុំបូកសរុប វាយតំលៃ រួចរាយការណ៍ពីលទ្ធផលជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីរាយការណ៍ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីពិនិត្យ និងមានវិធានការតាមការជាក់ស្តែង ។

**ប្រការ ៣ :** គណៈករណីនេះមានសិទ្ធិប្រើប្រាស់កងកំលាំងក្រោមឱវាទរបស់ខ្លួន ដើម្បីបំពេញភារកិច្ចខាងលើតាមការចាំបាច់ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងទ័ពជើងគោក និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០១៥......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា
## (ស.រ.ហ.ក)

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា(ស.រ.ហ.ក) សម្រាប់គ្រប់វិស័យអាជីវកម្មនៅកម្ពុជា ដោយឱ្យអនុវត្តទាំងស្រុងតាមរាល់ស្តង់ដារអន្តរជាតិ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (International Accounting Standard Board) ដោយរាប់បញ្ចូលទាំងការបកស្រាយ ទាំងការធ្វើបច្ចុប្បន្នកម្មដែលអាចកើតមានឡើងនៅគ្រប់កាលៈទេសៈ ចំពោះស្តង់ដារអន្តរជាតិនីមួយៗនោះផង ។

**ប្រការ ២.-**

រាល់សហគ្រាសធុនធំនិងមធ្យមដែលជាប់កាតព្វកិច្ច តាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានពេញលេញនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា(ស.រ.ហ.ក) ដែលចែងនៅប្រការ១ខាងលើ តាមសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ(ក.ជ.គ) ។

សហគ្រាសដទៃទៀតក្រៅពីនេះក៏អាចអនុវត្តតាមស.រ.ហ.កនេះបានដែរ ដោយពុំមានការខុសទាស់ឡើយ កាលបើសហគ្រាសទាំងនោះយល់ឃើញថាជាការចាំបាច់ នៅក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

**ប្រការ ៣.-**

ក្រុមប្រឹក្សាជាតិគណនេយ្យ(ក.ជ.គ)មានសិទ្ធិសម្រេចជ្រើសរើស ចេញសេចក្តីជូនដំណឹង និងផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ នូវស្តង់ដារអន្តរជាតិទាំងឡាយដែលត្រូវបានចេញផ្សាយដោយក្រុមប្រឹក្សាគណនេយ្យអន្តរជាតិរួចហើយនោះដោយគ្រាន់តែប្តូរចំណងជើងទៅជាស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា(ស.រ.ហ.ក) ឱ្យដល់គ្រប់សហគ្រាសដែលមានកាតព្វកិច្ចអនុវត្តតាម និងមានតម្រូវការអនុវត្តតាម ។

ទន្ទឹមគ្នានេះ ក្រុមប្រឹក្សាជាតិគណនេយ្យមានភារកិច្ចចាត់ចែងការបកប្រែសម្រួល នូវស្តង់ដារអន្តរជាតិនិមួយៗនោះជាមួយនឹងការបកស្រាយនិងបច្ចុប្បន្នកម្មជាបណ្តើរៗ មកជាភាសាជាតិ ។

**ប្រការ ៤.-**

ការមិនអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសនេះនឹងត្រូវចាត់ទុកជាការល្មើស ចំពោះមាត្រា ១៨ និង ១៩ នៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ២២១ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការដាក់ឱ្យប្រើស្តង់ដារគណនេយ្យកម្ពុជា(ស.គ.ក) និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.រ.ហ.ក) ត្រូវបានចាត់ទុកជានិរាករណ៍ និងជំនួសទាំងស្រុងដោយប្រកាសនេះ ។

**ប្រការ ៦.-**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ (**ក.ជ.គ**) ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា(**វ.គ.ស.ក**) និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងសហគ្រាសធុនធំនិងមធ្យមដែលជាប់កាតព្វកិច្ចតាមប្រការ២ខាងលើ ត្រូវអនុវត្តតាមតួនាទីរៀងៗខ្លួននូវប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ ស.ហ.វ

**"ដើម្បីជូនជ្រាបជាព័ត៌មាន"**

- គ្រប់ក្រសួង-ស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

**"ដើម្បីជូនជ្រាបនិងសហការអនុវត្ត"**

- ដូចប្រការ៦

**"ដើម្បីអនុវត្ត"**

- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០១ សហវ

# សារាចរណែនាំ

## ស្តីពីការអនុវត្តថវិកាខេត្ត ក្រុង ឆ្នាំ ២០០៩

ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៣៧ អនក្រ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ និងអនុក្រឹត្យលេខ ២៣៨ អនក្រ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។ ប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃ មាតិកា ថវិកា។ ដើម្បីអោយការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ មានដំណើរការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាពខ្ពស់និងសំរេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តថវិការបស់ខេត្ត ក្រុងសំរាប់ឆ្នាំ ២០០៩ ដែលមានតាមលំដាប់លំដោយដូចតទៅ៖

### ក. អំពីចំណូល

#### ១. ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ ជាគុណប្រយោជន៍នៃថវិកាខេត្ត ក្រុង នោះ ខេត្ត ក្រុងត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយនិងនីតិវិធីប្រមូលចំណូលរបស់មន្ត្រីពន្ធដារអោយបានត្រឹមត្រូវតាមបទប្បញ្ញាតិជាធរមាន និងត្រូវរួមចំណែកដាក់ចេញវិធានការដាក់ស្តែងសំរាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវអោយអ្នកជាប់ពន្ធ បង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់ និងទាន់ពេលវេលា ។ ទន្ទឹមនោះ ខេត្ត ក្រុងត្រូវចាត់អោយមានមន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យស្ថិតិ និងកម្រងព័ត៌មាន ដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធដារ សំរាប់ជាគុណប្រយោជន៍ដល់ថវិកាខេត្ត ក្រុង ដើម្បីជួយដល់មន្ត្រីពន្ធដារក្នុងការប្រមូលចំណូល និងធ្វើជាឯកសារបង្អែកក្នុងការរៀបចំគំរោងចំណូលពន្ធដារសំរាប់ឆ្នាំនីមួយៗ ។

#### ២. ចំណូលមិនមែនសារពើពន្ធ

ចំពោះចំណូលមិនមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ថវិកាខេត្ត ក្រុង នោះ ខេត្ត ក្រុងត្រូវយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូល ដែលត្រូវប្រមូលបង់ចូលរតនាគារអោយអស់មិនត្រូវទុក ចំណូលខ្លះ នៅដោយឡែក សំរាប់ចំណាយដោយឡែកក្រៅពីគំរោងចំណាយប្រចាំឆ្នាំឡើយ ។ ចំពោះចំណូលមិនមែនសារពើពន្ធដទៃទៀត ដែលខេត្ត ក្រុង បានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ ក៏ត្រូវបង់ចូលថវិកាខេត្ត ក្រុងដែរ ជៀសវាងទុកចំណូលនោះដោយឡែក សំរាប់ចំណាយដោយឡែក គ្មានតម្លាភាព ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ចំពោះមុខសញ្ញាចំណូលដែល បានកំណត់រួចហើយ បើក្នុងលក្ខណៈដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើអោយមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ ទន្ទឹមនោះត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលអោយបានត្រឹមត្រូវតាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា ។

ដោយឡែកសំរាប់ខេត្តបាត់ដំបង និងខេត្តសៀមរាបត្រូវជួយបង្គ្រប់លក្ខណៈសម្បត្តិអោយការប្រមូលចំណូលពីច្រកចេញចូលតែមួយរបស់ស្រុកបាត់ដំបង និងស្រុកសៀមរាបប្រព្រឹត្តទៅបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។

**៣. ចំណូលឧបត្ថម្ភពីថវិការដ្ឋ**

ចំពោះខេត្ត ក្រុង ដែលត្រូវបំពេញតុល្យភាពដោយការឧបត្ថម្ភពីថវិការដ្ឋ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភពីថវិការដ្ឋនៅក្នុងគំរោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថា ថវិការដ្ឋត្រូវតែដាច់ខាតឧបត្ថម្ភតាមចំនួននោះទេ ។ ចំណូលឧបត្ថម្ភពីថវិការដ្ឋ គឺត្រូវពិនិត្យឧបត្ថម្ភជូនខេត្ត ក្រុង ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតុល្យភាពថវិការដ្ឋ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តចំណូល ចំណាយថវិការបស់ខេត្ត ក្រុង ។

**៣.១ ចំណូលឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ**

ចំពោះចំណូលនេះ ខេត្ត ក្រុងត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ។ នៅដើមត្រីមាសទី ១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ថវិកាឧបត្ថម្ភតុល្យភាពជូនខេត្ត ក្រុង ដោយមិនបាច់មានការស្នើសុំទេ ។ ដោយឡែកសំរាប់ត្រីមាសទី ២ ទី ៣ និងទី ៤ខេត្ត ក្រុងត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាពនៅដើមខែនៃចុងត្រីមាសមុន សំរាប់ត្រីមាសបន្ទាប់ដោយភ្ជាប់មកជាមួយនូវឯកសារជាមូលដ្ឋាននៃការស្នើសុំឧបត្ថម្ភតុល្យភាព ។

**៣.២ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់វិនិយោគសាធារណៈ**

ចំណូលនេះ គ្រាន់តែជាការផ្ទេរឥណទានថវិការដ្ឋសំរាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណៈនៅក្នុងថវិកាខេត្ត ក្រុង ដូច្នេះពេលស្នើសុំគឺខេត្ត ក្រុង ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង ។ ការស្នើនេះ ចែកចេញជាពីរយ៉ាង ៖

**ទី១. ឧបត្ថម្ភសំរាប់ចូលនិធិបដិភាគ**

ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬ ប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគំរោងកម្មវិធីវិនិយោគសាធារណៈ នៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅខេត្ត ក្រុងរបស់ខ្លួន ។

**ទី២. ឧបត្ថម្ភវិនិយោគដោយថវិការដ្ឋ**

ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ ។

## ខ. អំពីចំណាយ

**១. ចំណាយចរន្ត :**

ចំណាយចរន្តត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ ទៅតាមគោលការណ៍ និងនីតិវិធីដូចគ្នា នៃចំណាយថវិការដ្ឋដែរពោលគឺ ៖

- អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់ ។ ចំពោះបៀវត្សមូលដ្ឋាន និងប្រាក់កំរៃបុគ្គលិកអណ្តែត ភ្នាក់ងារជាប់កិច្ចសន្យា ត្រូវអនុវត្តតាមសេចក្តីសំរេចទទួលស្គាល់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរដ្ឋទេយ្យបុរេប្រទានដែលកំណត់ឡើងដោយដីការបស់ខេត្ត ក្រុង ។ ពេលដកប្រាក់ពីរតនាគារ រដ្ឋទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំថ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។

- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តទៅតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬសេវានានា ត្រូវបានអនុវត្តរួចហើយ ។

- ចំពោះជំពូក ០៩ "ចំណាយមិនបានគ្រោងទុក" ខេត្ត ក្រុងមិនត្រូវអនុវត្តចំណាយជំពូកនេះដោយផ្ទាល់ទេ ។ នៅពេលមានតំរូវការចំណាយខេត្ត ក្រុងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀត ទៅតាមតំរូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសអាទិភាពសំរាប់តំរូវការប្រាក់បៀវត្ស និងការងារអភិវឌ្ឍន៍ខេត្ត ក្រុង ។

- ដោយឡែកសំរាប់ខេត្តបាត់ដំបង និងខេត្តសៀមរាប ឯកឧត្តមអភិបាលខេត្ត ត្រូវចេញដីកាផ្ទេរឥណទាន និងផ្ទេរអាណាប័កជូនអភិបាលស្រុកបាត់ដំបង និងស្រុកសៀមរាប អោយអនុវត្តនូវចំនួនឥណទានដែលខេត្តបានពិភាក្សាឯកភាពជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចដែលបានបែងចែក និងភ្ជាប់ជាមួយក្នុងសៀវភៅថវិការបស់ខេត្តបាត់ដំបង និងខេត្តសៀមរាបរួចហើយនោះ ។

**២. ចំណាយជាមូលធន :**

ចំពោះការចំណាយជាមូលធនគឺចែកចេញជាពីរ ៖

**ទី១. ចំណាយសំរាប់មូលនិធិបដិភាគ :**

ក្នុងពេលអនុវត្ត ខេត្ត ក្រុងត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់តាមនូវគំរោងកម្មវិធីវិនិយោគសាធារណៈនៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ ។ រតនាគារខេត្ត ក្រុង ត្រូវបើកផ្តល់ឬផ្ទេរឥណទាននេះទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគារខេត្ត ក្រុង ឬធនាគារ (បើមាន) ។

**ទី២. ចំណាយវិនិយោគ :**

ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិកាខេត្ត ក្រុង ឬហិរញ្ញប្បទានដោយថវិការដ្ឋឧបត្ថម្ភក៏ដោយគឺត្រូវតែបំពេញបែបបទ និងអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន និងធ្វើអាណត្តិទូទាត់អោយបានត្រឹមត្រូវតាមការិយបច្ចេទដែលបានកំណត់ក្នុងសៀវភៅបន្ទុក ឬ កិច្ចសន្យា ។

**៣. ចំណាយបន្ថែមលើសពីគំរោងចំណាយថវិកាខេត្ត ក្រុងប្រចាំឆ្នាំ :**

យោងប្រការ ១២ នៃ ប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង បានចែងថា ឲ្យនៅក្នុងឆ្នាំថវិកាប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់ខេត្ត ក្រុង បានកើនលើសពីគំរោងចំណូលប្រចាំឆ្នាំ ដែលបានគ្រោងទុកនោះឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកំរិតចំណូលលើសដែលបានចុះកិច្ចបញ្ជីការ ។

ដូច្នេះ នៅត្រីមាសទី ៤ ខេត្ត ក្រុងត្រូវពិនិត្យការអនុវត្តចំណូលរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគំរោងចំណូលប្រចាំឆ្នាំ ។ ប្រសិនបើមានចំណូលលើសពីគំរោងចំណូលប្រចាំឆ្នាំ ខេត្ត ក្រុងអាចស្នើសុំបន្ថែមលើគំរោងចំណាយប្រចាំឆ្នាំសំរាប់ចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដែលជាចំណាយសំរាប់វិនិយោគអភិវឌ្ឍន៍ខេត្ត ក្រុង ហើយខេត្ត ក្រុងត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗផង ។

## គ. ការបង្វែរឥណទាន

ចាប់ពីឆ្នាំ ២០០៧ តទៅ ការរៀបចំគំរោង និងការអនុវត្តថវិកាត្រូវកត់ត្រាទៅតាមប្លង់គណនេយ្យ និង មាតិកាថវិកាថ្មី ដែលមានបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ។

ការបង្វែរ (និយ័តភាព) ឥណទានត្រូវបានអនុញ្ញាតដោយអនុវត្តចាប់ពីត្រីមាសទី ២ ។ ក្នុងករណីមាន តំរូវការចាំបាច់ត្រូវបង្វែរឥណទានពីអនុគណនីមួយទៅអនុគណនីមួយ ពីគណនីមួយទៅគណនីមួយ និងពីជំពូកមួយ ទៅជំពូកមួយផ្សេងទៀតនោះខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍អនុវត្តចំណាយដើមឆ្នាំ និងរបាយការណ៍ចាន់ស្មានចំណាយចុងឆ្នាំ ។

## ឃ. ការរៀបចំកម្មវិធីចំណូល ចំណាយ

ផ្អែកលើគំរោងថវិកាប្រចាំឆ្នាំ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសជូន ខេត្ត ក្រុងទាំងអស់ ត្រូវរៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស និងត្រូវផ្ញើកម្មវិធីចំណូល ចំណាយនោះទៅរតនាគារខេត្ត ក្រុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតមួយសប្តាហ៍នៃដើមត្រីមាសនីមួយៗ ។ ដោយឡែកសំរាប់ត្រីទី ២ ទី ៣ និងទី ៤ ពេលផ្ញើកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺដាច់ខាតត្រូវតែភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការអនុវត្តថវិកានៃត្រីមាសមុន។ កម្មវិធីចំណូល ចំណាយប្រចាំត្រីមាស គឺជាឯកសារគោល ដើម្បីវិភាគក្នុងការផ្តល់ឧបត្ថម្ភគុល្យភាពពីថវិការដ្ឋ ។

ក្នុងការអនុវត្តថវិការបស់សាលាខេត្ត ក្រុង ក្រុមហិរញ្ញវត្ថុត្រូវធ្វើជាសេនាធិការអោយអភិបាលខេត្ត ក្រុង ក្នុងការរៀបចំរាល់សំណុំលិខិត ឯកសារទាំងអស់ដែលពាក់ព័ន្ធដល់ការងារជំនាញហិរញ្ញវត្ថុ ថវិកា ដើម្បីជំរុញអោយ ការអនុវត្តចំណូល និងចំណាយថវិការបស់សាលាខេត្ត ក្រុងសំរេចបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។

ខាងលើនេះគឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិកាខេត្ត ក្រុងអោយចំទិសដៅនិងមានប្រសិទ្ធភាព សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដោយឡែកប្រកាសណែនាំស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង លេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះ នៅតែរក្សាសុពលភាពដដែល ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

  (ដើម្បីជូនជ្រាប)

- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង
- គ្រប់រតនាគារខេត្ត ក្រុង
- គ្រប់សាខាពន្ធដារខេត្ត ក្រុង

  (ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ